**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ
## សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
## ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
## ក្នុងឱកាសទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២៣

***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត***

ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១១២ នៃទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២៣ នេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវគារវកិច្ច និងអំណរសាទរដោយស្មោះអស់ពីដួងចិត្តថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ក្នុងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លា ជាព្រះប្រធានកិត្តិយស កាកបាទក្រហមកម្ពុជានិងក្រុមប្រឹក្សាជាតិដើម្បីស្ត្រី និងសូមលំឱនកាយ លើកអញ្ជលីប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យនិងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក មានទេវតារក្សាព្រះមហាស្វេតច្ឆ័ត្រ ព្រះបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រយានី ពិសេសបុណ្យបារមីរបស់ **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** សូមប្រទានព្រះរាជសព្ទសាធុការពរ បវរសួស្តី សិរីមង្គលវិបុលសុខមហាប្រសើរថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមព្រះអង្គសមប្រកបនូវព្រះពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមទ្រង់ព្រះមេត្តាទទួលនូវអភិនន្ទនកិច្ច និងព្រះសេយ្យកក្តីដ៏ស្មោះស្ម័គ្របំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ សុក្រ ១២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រុំ សុខា**